00282981

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

C20/5/13

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 02 / 2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១៦)

## <u>របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង</u>

I) **នីតិវិធី**

II) **ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

### I) នីតិវិធី

### ក) សេចក្តីផ្តើម

អនុលោមតាមវិធាន៧៧(១០) នៃវិធានផ្ទៃក្នុង របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“វិធានផ្ទៃក្នុង”) ប្រធានអង្គបុរេជំនុំជម្រះបានចាត់តាំងលោកចៅក្រម **ហួត វុទ្ធី** និងលោកចៅក្រម Rowan Downing ឱ្យធ្វើរបាយការណ៍បង្ហាញលម្អិតអំពីអង្គហេតុ និងអង្គច្បាប់ នៅក្នុងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចេញដោយសហចៅក្រមស៊ើបអង្កេត ដែលដីកាបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវបានប្តឹងឧទ្ធរណ៍។ ប្រធានអង្គបុរេជំនុំជម្រះក៏បានឱ្យចៅក្រមទាំងពីររូបធ្វើការពិនិត្យសំណុំរឿង លេខ:០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១៦) ផងដែរ។

## <u>អត្តសញ្ញាណសម្គាល់ជនត្រូវចោទ:</u>

**អៀង ធីរិទ្ធ** ហៅ “**ភា**” ភេទស្រី កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ប្រទេសកម្ពុជា សញ្ជាតិ ខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន នៅផ្ទះលេខ ៤៧បេ ផ្លូវលេខ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ។ ឪពុកឈ្មោះ **ខៀវ អុន** (ស្លាប់) ម្តាយឈ្មោះ **អ៊ុក ប៉ុន** (ស្លាប់)។

C20/5/13



**អៀង ធីរិទ្ធ** មានសហមេធាវីការពារក្ដីរបស់គាត់គឺ លោក **ផាត់ ពៅស៊ាង** និង កញ្ញា Diana ELLIS។

**<u>បទចោទប្រកាន់:</u>**

**អៀង ធីរិទ្ធ** ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត) ដែលជាបទល្មើសមានចែង និងផ្ដន្ទាទោសតាមមាត្រា ៥, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់អ.វ.ត.ក")។

**គោលបំណងនៃរបាយការណ៍**

របាយការណ៍របស់សហចៅក្រមរបាយការណ៍នេះ បង្ហាញលម្អិតអំពីអង្គហេតុ និងអង្គច្បាប់នៅក្នុងសេចក្ដីសម្រេចដែលត្រូវបានប្ដឹងឧទ្ធរណ៍ និងអង្គហេតុដែលពាក់ព័ន្ធផ្សេងៗទៀតនៅចំពោះមុខតុលាការ។ របាយការណ៍នេះ ផ្ដល់ជាជំនួយដល់អ្នកដែលមិនមែនជាភាគីនៃនីតិវិធី ឱ្យយល់អំពីរឿងក្ដីនេះ នៅចំពោះមុខតុលាការ។

**ខ) ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឱ្យបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន**

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន លើ **អៀង ធីរិទ្ធ** ដែលត្រូវបានឃុំខ្លួនចាប់តាំងពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំ ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ៦៣-៦(ក) នៃវិធានផ្ទៃក្នុង[១]។

សហចៅក្រមស៊ើបអង្កេតបានរកឃើញថា លក្ខខណ្ឌទីមួយដើម្បីចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ដែលមានចែងនៅក្នុងវិធាន៦៣-៣(ក) នៅតែត្រូវបានបំពេញ ដោយសារតែមានហេតុផលដែលនាំឱ្យជឿជាក់ច្បាស់ថា ជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលគាត់ត្រូវបានគេចោទ

---

[១] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, C20/4 ("ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួន") ទំព័រទី៩។

ប្រកាន់"[២]។ ក្នុងការចេញដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេតបានផ្អែកទាំងស្រុងលើការវិភាគសំណុំរឿងដែលរៀបចំឡើងដោយអង្គបុរេជំនុំជម្រះ នៅពេលអង្គបុរេជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នដំបូង។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបែបនេះ មិនទាន់មានភស្តុតាងណាមួយផ្សេងមកដោះបន្ទុកនៅឡើយទេ។

សហចៅក្រមស៊ើបអង្កេតបានរកឃើញថា គ្មានការផ្លាស់ប្តូរស្ថានភាព ចាប់តាំងពីអង្គបុរេជំនុំជម្រះបានសម្រេចថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់ដើម្បីធានាវត្តមានរបស់ជនត្រូវចោទក្នុងអំឡុងពេលដំណើរការនីតិវិធី ការពារសន្តិសុខឱ្យជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា មូលហេតុទាំងបី ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង៦៣-៣(ខ) នៅតែត្រូវបានបំពេញនៅឡើយ[៣]។

សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនអស់រយៈពេលប្រមាណជាជិត១២ខែ មិនមាន "លក្ខណៈហួសហេតុទេ បើគិតពីទំហំនៃកិច្ចស៊ើបសួរ ភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបញ្ជូនមកសហចៅក្រមស៊ើបអង្កេត"[៤]។ សហចៅក្រមស៊ើបអង្កេត បានលើកឡើងបន្ថែមទៀតថា ការអនុវត្តសិទ្ធិនៅស្ងៀមរបស់ជនត្រូវចោទ "មិនបានចូលរួមចំណែកដល់ការពន្យឺតនីតិវិធីទេ"[៥] ទោះបីជាសិទ្ធិនេះត្រូវបានទទួលស្គាល់ និងមិនអាចជំទាស់បានក៏ដោយ។

## គ) បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលនៅក្នុងបណ្តឹងនោះ សហមេធាវីការពារក្តីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (១) សម្រេចថា លក្ខខណ្ឌតឹងរ៉ឹងសម្រាប់បន្តថិរវេលាឃុំខ្លួនជនត្រូវចោទលែងជាលក្ខខណ្ឌដែលត្រូវបានបំពេញទៀតហើយ (២) ចាត់ទុកជាមោឃៈចំពោះដីកាសម្រេចអំពីការបន្តថិរវេលាមួយឆ្នាំនៃការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ និង(៣) សម្រេចដោះលែងជនត្រូវ

---

[២] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ១៣

[៣] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ ២១ ដល់ ៣៤។

[៤] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ ៣៦។

[៥] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួន កថាខណ្ឌ ៣៧។

ចោទជាបន្ទាន់ តាមលក្ខខណ្ឌដែលអង្គបុរេជំនុំជម្រះយល់ឃើញថាសមស្រប[៦]។ សហមេធាវីការពារក្តីប្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមិនមានហេតុផលគ្រប់គ្រាន់ និងសហចៅក្រមស៊ើបអង្កេតមិនបានធ្វើការស៊ើបអង្កេតរបស់ខ្លួនដោយយកចិត្តទុកដាក់។

## ឃ) ចម្លើយតបរបស់សហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញាសន្និដ្ឋានក្នុងចម្លើយតបថា បណ្តឹងឧទ្ធរណ៍គួរតែបដិសេធចោលទាំងស្រុងដោយសារតែជនត្រូវចោទមិនបានបង្ហាញអំពីការផ្លាស់ប្តូរស្ថានភាពណាមួយ ចាប់តាំងពី **អៀង ធីរិទ្ធ** ត្រូវបានសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនគាត់។

## II. ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍

## ក) សេចក្តីសម្រេចដែលមានមូលហេតុមិនគ្រប់គ្រាន់

សហមេធាវីការពារក្តីបានលើកអំណះអំណាងដូចខាងក្រោមថា៖

> "ដោយហេតុថា [សហចៅក្រមស៊ើបអង្កេត] (i) មិនបានផ្តល់មូលហេតុគ្រប់គ្រាន់ចំពោះការអះអាងរបស់ខ្លួន (ii) បានផ្តល់នូវព័ត៌មានមិនពិតទាក់ទិនទៅនឹងភស្តុតាងដែលត្រូវបានលើកឡើងប្រឆាំងនឹងជនត្រូវចោទ និង (iii) បានផ្តល់នូវព័ត៌មានមិនគ្រប់គ្រាន់ ឬព័ត៌មានមិនពិតស្តីពីសិទ្ធិពិនិត្យមើលសំណុំរឿងរបស់ជនត្រូវចោទ ដីកាសម្រេចអំពីការបន្តចិរវេលាឃុំខ្លួនខ្វះខាតនូវអំណះអំណាង ដែលរំលោភទៅលើវិធាន ៦៣-៧ នៃវិធានផ្ទៃក្នុង និងគោលការណ៍ច្បាប់ទូទៅដែលបានបញ្ជាក់ពីខាងលើ។ កង្វះខាតបែបនេះគួរតែនាំឲ្យមានការទុកជាមោឃៈនូវដីកាសម្រេចអំពីការបន្តចិរវេលាឃុំខ្លួននេះ"[៧]។

---

[៦] បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ ជំទាស់ "ដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន" ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស-អបជ(១៦) ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨ C20/5/1 "បណ្តឹងឧទ្ធរណ៍" កថាខណ្ឌ២១ ដល់២១។

[៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៥

00282985

C20/5/13



សហព្រះរាជអាជ្ញាសន្និដ្ឋានថា "ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនធ្វើដោយ[សហចៅក្រមស៊ើបអង្កេត] គឺមានលក្ខណៈគ្រប់គ្រាន់ និងសមល្មម៖ [សហចៅក្រមស៊ើបអង្កេត] បានដាក់ចេញដោយលើកយកមកពិចារណាអំពីមូលហេតុផ្នែកច្បាប់ និងអង្គហេតុមុននឹងចេញដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន ហើយក៏មិនជាប់កាតព្វកិច្ចត្រូវបញ្ជាក់ពីកត្តានានាទាំងអស់នោះដែរ។ ផ្ទុយពីអ្វីដែលមេធាវីការពារក្តីបានលើកឡើង ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនមិនមានព័ត៌មានខុសណាមួយទេ ហើយការពិត ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានទទួលសិទ្ធិពិនិត្យធាតុផ្សំទាំងអស់នៃសំណុំរឿង តាមរយៈមេធាវីការពារក្តីរបស់ខ្លួន"[៨]។

## ខ) ការយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត

សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកអំណះអំណាងថា សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តកិច្ចស៊ើបអង្កេតដោយ "យកចិត្តទុកដាក់ពិសេស" នោះទេ ដោយសារតែសហចៅក្រមស៊ើបអង្កេតខកខានមិនបានប្រមូលភស្តុតាងដាក់បន្ទុកលើជនត្រូវចោទ ដើម្បីគាំទ្របទចោទដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅក្នុងអំឡុងពេលដែលជនត្រូវចោទត្រូវបានឃុំខ្លួន[៩]។ សហមេធាវីការពារក្តីបានតវ៉ាថា សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តកិច្ចស៊ើបអង្កេតដោយយកចិត្តទុកដាក់ ដោយត្រូវតែបង្ហាញឱ្យឃើញតាមរយៈការប្រមូលភស្តុតាង ក្នុងអំឡុងពេលជនត្រូវចោទកំពុងជាប់ឃុំ មិនមែនតាមតែរយៈវិសាលភាពនៃកិច្ចស៊ើបអង្កេតនោះទេ[១០]។

សហមេធាវីការពារក្តីបានលើកឡើងថា "កិច្ចស៊ើបអង្កេតគ្របដណ្តប់លើអង្គហេតុស្មុគស្មាញមួយចំនួន ប៉ុន្តែប្រសិនបើ [សហចៅក្រមស៊ើបអង្កេត] ក្នុងរយៈពេលមួយឆ្នាំនេះ មិនអាចមានលទ្ធភាពបង្ហាញភស្តុតាងដាក់បន្ទុកណាមួយ ទៅលើជនត្រូវចោទ ក្រៅតែពីជាការអះអាងថាជនត្រូវចោទជា

---

[៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី **អៀង ធីរិទ្ធ** ប្រឆាំងនឹង "ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២00៨" ថ្ងៃទី៩ ខែមករា ឆ្នាំ២00៩, C20/5/7 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ២(ក)។

[៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣២ ដល់៣៣

[១០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣៦

C70/5/13

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៦)

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនោះ ដូច្នេះបានសេចក្តីថាភាពស្មុគស្មាញ ឬវិសាលភាព នៃកិច្ចស៊ើបសួរ គឺមិនមែនជាបញ្ហាជាប់ពាក់ព័ន្ធអ្វីនឹងបញ្ហានេះទេ ឬមិនមាននិយាមគ្រប់គ្រាន់ទេ[១១]"។

សហមេធាវីការពារក្តីបានតវ៉ាបន្ថែមទៀតថា "ការដាក់ចេញនូវដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដោយទម្លាក់កំហុសចំពោះការយឺតយ៉ាវ ទៅលើមេធាវីការពារក្តីនោះ គឺជាការរំលោភបំពានសិទ្ធិនៅស្ងៀមមិនឆ្លើយតប[១២]"។

សហព្រះរាជអាជ្ញា សន្និដ្ឋានក្នុងចម្លើយតបថា "មេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញថា រយៈពេលនៃការឃុំខ្លួននោះ បានធ្វើឱ្យក្តីរបស់ [ជនត្រូវចោទ] ការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ និង/ឬដើម្បីបង្ហាញថាតើវាអាចផ្តល់ការឃុំខ្លួន"[១៣]។ សហព្រះរាជអាជ្ញាបន្ថែមទៀតថា ថិរវេលានៃឃុំខ្លួនមុនពេលជំនុំជម្រះគឺមានលក្ខណៈសមស្រប ដោយសារតែមានការចោទប្រកាន់អំពីបទឧក្រិដ្ឋធ្ងន់ធ្ងរ លក្ខណៈស្មុគស្មាញនៃករណីរឿងក្តី និងកម្រិតនៃការស៊ើបសួរដែលកំពុងតែអនុវត្តដោយសហចៅក្រមស៊ើបអង្កេត[១៤]។

សហព្រះរាជអាជ្ញាក៏សន្និដ្ឋានថា "ការធ្វើឱ្យខូចដល់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ [ជនត្រូវចោទ] ដូចដែលបានលើកឡើង ហាក់ដូចជាបានផ្អែកទៅលើការអានដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន មិនបានត្រឹមត្រូវ។ សិទ្ធិនៅស្ងៀមមិនឆ្លើយតប ត្រូវបានទទួលស្គាល់ និងមិនមានការជំទាស់ពី [សហចៅក្រមស៊ើបអង្កេត]ទេ"។ ទោះជាយ៉ាងណាក៏ដោយ អវត្តមាននៃកិច្ចសហការរបស់[ជនត្រូវចោទ] មិនបានជួយដល់[សហចៅក្រមស៊ើបអង្កេត] នៅក្នុងការស្វែងរកភស្តុតាងដោះបន្ទុកឡើយ"[១៥]។

**គ) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធានផ្ទៃក្នុង ៦៣-៣(ក))**

---

[11] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣៦

[12] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥៦

[13] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣០

[14] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣០

[15] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២.គ

00282987

C20/5/13



សហព្រះរាជអាជ្ញាសន្និដ្ឋានថា "បញ្ហាជាចំបងនៅក្នុងការកំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួននេះ ថាតើលក្ខខណ្ឌនានាដូចបានកំណត់នៅក្នុងវិធាន ៦៣-៣ នៅតែត្រូវបានបំពេញ ឬយ៉ាងណានោះទេ"[១៦]។ សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមថា ក្នុងករណីដែលថា អង្គបុរេជំនុំជម្រះអាច "ធ្វើការវិភាគផ្ទាល់ខ្លួន និងដោះស្រាយវិការៈដែលមានក្នុងដីកាសម្រេចនោះ តាមរយៈការដាក់ជំនួសនូវសម្អាងហេតុរបស់ខ្លួនផ្ទាល់ ក៏ទឡ្ហីករណ៍ភាគច្រើនដែលលើកឡើងដោយជនត្រូវចោទនៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ មិនមានពាក់ព័ន្ធជាសារវ័ន្តនោះទេ។

សហព្រះរាជអាជ្ញាបានបង្ហាញថា មេធាវីការពារក្តីមិនបានធ្វើការតវ៉ាប្រឆាំងនឹងអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញ ដែលនាំឱ្យមានការជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[១៧]។ តាមយោបល់របស់សហព្រះរាជអាជ្ញា ការរកឃើញរបស់អង្គបុរេជំនុំជម្រះដែលថា លក្ខខណ្ឌដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៣-៣(ក) ដែលបានបំពេញ ត្រូវបានបញ្ជាក់អះអាងបន្ថែមដោយការប្រមូលភស្តុតាងថ្មីៗ ចាប់តាំងពីការចេញសេចក្តីសម្រេចនោះមក[១៨]។

## គ) ការពិចារណាអំពីមូលហេតុដែលធ្វើឱ្យការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់ (វិធានផ្ទៃក្នុង ៦៣-៣(ខ))

សហមេធាវីការពារក្តីបានលើកអំណះអំណាងថា សហចៅក្រមស៊ើបអង្កេតបានខកខានក្នុងការវែកញែកហេតុផល ឬផ្តល់ភស្តុតាងណាមួយនៅក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនរបស់ខ្លួន ដែលបញ្ជាក់ថាមាន "ហានិភ័យពិតប្រាកដមែន" ដែលថាសាក្សីទាំងអស់អាចនឹងប្រកែកមិនព្រមចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ប្រសិនបើជនត្រូវចោទត្រូវបានដោះលែងនោះ[១៩]។ សហមេធាវីការពារក្តី

---

[១៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥

[១៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣៦

[១៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣៩

[១៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦០

00282988

C 20/5/13



បានលើកឡើងថា បទដ្ឋានដំបូងនៃការបង្ហាញភស្តុតាង លែងមានសុពលភាពគ្រប់គ្រាន់ ក្រោយពីការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលមួយឆ្នាំហើយនោះ[២០]។

សហព្រះរាជអាជ្ញាបានឆ្លើយតបថា "[ជនត្រូវចោទ]មិនបានបង្ហាញអំពីការផ្លាស់ប្តូរស្ថានភាព ដើម្បីបង្ហាញថា លក្ខខណ្ឌចាំបាច់សម្រាប់ឃុំខ្លួនគាត់ ដែលមានចែងនៅក្នុងវិធាន៦៣-៣(ខ) មិនបានបំពេញទៀតឡើយ" និងមិនបានតវ៉ាជំទាស់ថា លក្ខខណ្ឌទាំងបួន ក្នុងចំណោមលក្ខខណ្ឌទាំងប្រាំ មិនត្រូវបានបំពេញនោះទេ[២១]។

សហព្រះរាជអាជ្ញាសន្និដ្ឋានថា "អាកប្បកិរិយារំលោភបំពាន" របស់ជនត្រូវចោទនៅក្នុងពេលសវនាការរបស់អង្គបុរេជំនុំជម្រះនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ "គឺមានលក្ខណៈជាការគម្រាមកំហែង និងប៉ុនប៉ងក្នុងការបំភិតបំភ័យភាគីនានា និង/ឬចំពោះចៅក្រម" ដែលគួរត្រូវយកចិត្តទុកដាក់ ក្នុងពេលដែលធ្វើការវាយតម្លៃអំពីហានិភ័យផ្សេងៗដែលអាចកើតឡើងដល់សាក្សី និងជនរងគ្រោះនានា និងសន្តិសុខផ្ទាល់របស់ជនត្រូវចោទ ដែលមានចែងនៅក្នុងវិធាន៦៣-(ខ)(៤) និង៦៣-(ខ)(៥)[២២]។ សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមទៀតថា "សេចក្តីថ្លែងការណ៍ថ្មីៗនេះ និងអាកប្បកិរិយារបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានបង្ហាញឱ្យឃើញថា ការដោះលែងជនណាម្នាក់ក្នុងចំណោមជនត្រូវចោទទាំងប្រាំ(៥)រូប អាចនឹងធ្វើឱ្យប្រែក្លាយទៅជាអំពើហិង្សាសំដៅប្រឆាំងចំពោះអតីតមេដឹកនាំខ្មែរក្រហមទាំងនោះ ដែលរួមមាន[ជនត្រូវចោទ] ក្រុមមេធាវីការពារក្តី ឬអ.វ.ត.កផង"[២៣]។

ភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង ចៅក្រម Rowan Downing

---

[២០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦០

[២១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៤៥ និង៤៦។

[២២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៤៧ ដល់៥១។

[២៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥២។